**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ០៩៥ សហវ

# ប្រកាស

## ស្តីពីការអនុញ្ញាតអោយប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុ និង រដ្ឋបាលសំរាប់កម្មវិធីសិលា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស /៩៤ ចុះថ្ងៃទី ខែ២០ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ. បក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា
- យោងប្រកាសលេខ ២៩២ គ.ជ.ន.ស ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០០២ ស្តីពីការរៀបចំរចនាសម្ព័ន្ធ និងតួនាទីភារៈកិច្ចរបស់គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុងនៃកម្មវិធីសិលា
- យោងតាមអនុសាសន៍របស់អង្គសិក្ខាសាលាជាតិ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងរដ្ឋបាលសិលា ដែលបានរៀបចំឡើងនៅថ្ងៃទី ០១.០២ ខែ សីហា ឆ្នាំ ២០០២ នៅខេត្តពោធិសាត់

**សំរេច**

**ប្រការ ១ :** គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងអភិបាលខេត្ត-ក្រុង ត្រូវអនុវត្តតាមនីតិវិធី និងបទប្បញ្ញត្តិដូចដែលមានចែងនៅក្នុងសៀវភៅណែនាំ ដែលបានជូនភ្ជាប់មកជាមួយនេះ។

**ប្រការ ២ :** គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងអភិបាលខេត្ត-ក្រុង មានសិទ្ធិប្រើប្រាស់គណនីនៅធនាគារពាណិជ្ជកម្ម សំរាប់គ្រប់គ្រងហិរញ្ញប្បទានបរទេស ដែលបានផ្តល់ជូនសំរាប់អនុវត្តផែនការវិនិយោគសិលា។

គណនីធនាគារខាងលើត្រូវបើកក្នុងនាមគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ឬ គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង ក្រោមការគ្រប់គ្រងរបស់ប្រធានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ឬ អភិបាលខេត្ត-ក្រុង។

**ប្រការ ៣** : អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ប្រធានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុង និង ប្រធានរតនាគារខេត្ត-ក្រុង ដែលជាលេខាធិការរបស់គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវជួយណែនាំមុខជំនាញ ដល់គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង ក្នុងការអនុវត្តន៍ប្រព័ន្ធហិរញ្ញវត្ថុសិលានេះ។

**ប្រការ ៤** : អភិបាលខេត្ត-ក្រុងដែលជាប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង ត្រូវតែងតាំងមន្ត្រីសវនកម្មផ្ទៃក្នុង។ មន្ត្រីសវនកម្មផ្ទៃក្នុងនេះ ត្រូវបំពេញការជាបុគ្គលិកពេញម៉ោងរបស់គណៈកម្មាធិការប្រតិបត្តិនៃ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង ។ មន្ត្រីសវនកម្មផ្ទៃក្នុងត្រូវរាយការណ៍ដោយផ្ទាល់ជូនអភិបាលខេត្ត-ក្រុង អំពីការផ្ទៀងផ្ទាត់ និងត្រួតពិនិត្យការអនុវត្តន៍ប្រព័ន្ធហិរញ្ញវត្ថុសិលារបស់គ្រប់ភ្នាក់ងារសិលាទាំងអស់នៅថ្នាក់ខេត្ត-ក្រុង ។

**ប្រការ ៥** : ប្រកាសលេខ ៤៧០ សហវ.ហក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការអនុញ្ញាតអោយប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុវិមជ្ឈការសិលា និងប្រកាសលេខ ១៨៧ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីការកែសំរួលសៀវភៅណែនាំហិរញ្ញវត្ថុសិលា ព្រមទាំងបទប្បញ្ញត្តិទាំងឡាយណារបស់គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធិសិលា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦** : ប្រធានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា អភិបាលខេត្ត-ក្រុង និងប្រធានមន្ទីរហិរញ្ញវត្ថុខេត្ត-ក្រុង ត្រូវទទួលខុសត្រូវអនុវត្តប្រកាសនេះ។

**ប្រការ ៧** : ប្រកាសនេះមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០០៣

គាត ឈន់

<u>ចំលងជូន :</u>

- ខុទ្ទកាល័យព្រះមហាក្សត្រ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

- អភិបាលខេត្ត-ក្រុង
- គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា

"ដើម្បីអនុវត្ត"

- កាលប្បវត្តិ-ឯកសារ